# មជ្ឈមណ្ឌលឯកសារកម្ពុជា

## បទសម្ភាសន៍ជាមួយឈ្មោះ ណុប មុំ ភេទស្រី អាយុ៩០ឆ្នាំ
## ជនរងគ្រោះខ្មែរក្រហម «ពេទ្យស្រុកអង្គរជ័យ»
## ភូមិទទឹងថ្ងៃ ឃុំដារទង ស្រុកត្រាំកក់ ខេត្តតាកែវ ។
## ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១
## សម្ភាសដោយៈ ឡុង ដានី

ឡុង ដានីៈ មីងជាជំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអី?

ណុប មុំៈ ឈ្មោះ ណុប មុំ ។

ឡុង ដានីៈ ចឹងសព្វថ្ងៃមីងអាយុប៉ុន្មានហើយ?

ណុប មុំៈ អាយុ៩០ហើយ ។

ឡុង ដានីៈ ចឹងមីងនៅភូមិនេះគេហៅភូមិអីដែរ?

ណុប មុំៈ ភូមិទទឹងថ្ងៃ ពីដើមគេហៅក្បាលអូរ ។

ឡុង ដានីៈ ចឹងទទឹងថ្ងៃគេចាប់ហៅតាំងពីពេលណាមក?

ណុប មុំៈ ទទឹងថ្ងៃគេចាប់ហៅកាលឆ្នាំ៧៩ហ្នឹងមក ។

ឡុង ដានីៈ ឃុំអី?

ណុប មុំៈ ឃុំដារទង ។

ឡុង ដានីៈ ស្រុកត្រាំកក់ ខេត្តតាកែវ?

ណុប មុំៈ ចាស ។

ឡុង ដានីៈ ចឹងគ្រួសារមីងឈ្មោះអីដែរ?

ណុប មុំៈ ខ្ញុំមិនមានទេ ខ្ញុំមេម៉ាយ ។

ឡុង ដានីៈ ចឹងមីងមេម៉ាយតាំងពីពេលណាមក?

ណុប មុំៈ តាំងពីឆ្នាំ២០០០ ។

ឡុង ដានីៈ ហេតុអីមីងលែងគ្នាឬមួយយ៉ាងម៉េច?

ណុប មុំៈ លែងគ្នា ។

ឡុង ដានីៈ គាត់ឈ្មោះអីដែរ?

ណុប មុំៈ ឈ្មោះ សួង រ៉េត ។

ឡុង ដានី:	ចឹងមីងមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

ណុប មុំ:	មានកូន៧នាក់ ។

ឡុង ដានី:	ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ណុប មុំ:	ស្រី៤ប្រុស៣ ។

ឡុង ដានី:	ចឹងមីងសព្វថ្ងៃប្រកបមុខរបរធ្វើអីដែរ?

ណុប មុំ:	ធ្វើស្រែ ។

ឡុង ដានី:	ចឹងខ្ញុំចង់ឲ្យមីងរៀបរាប់ពីជីវិតទាក់ទងរបស់មីងកាលពីក្មេងមកធ្លាប់រៀនសូត្រអីណាបន្ទាប់ពីរៀនសូត្រហើយមីងធ្វើអីទៀត?

ណុប មុំ:	កាលពីតូចមិនដែលបានរៀនផង  រៀនបានមួយឆ្នាំកាលឆ្នាំ៧០ គេបាតុកម្មអីហ្នឹងនៅតាមជនបទលែងរៀនទៅ រៀនតិចតួចគ្រាន់មើលរួច ។

ឡុង ដានី:	រៀននៅសាលាណា?

ណុប មុំ:	វត្តមឿងចារ ។

ឡុង ដានី:	រៀននៅសាលាវត្តមឿងចារហ្នឹងបានប៉ុន្មានឆ្នាំដែរ?

ណុប មុំ:	រៀនបានមួយឆ្នាំ ។

ឡុង ដានី:	ចឹងរៀនបានមួយឆ្នាំគេរដ្ឋប្រហារឆ្នាំ៧០ទៅ?

ណុប មុំ:	ចាស ។

ឡុង ដានី:	ចឹងពេលរដ្ឋប្រហាហើយធ្វើអីទៀតទៅ?

ណុប មុំ:	នៅតូចមានធ្វើអីផង នៅផ្ទះធ្វើស្រែធ្វើអីជាម៉ែឪទៅ ។

ឡុង ដានី:	ចឹងនៅធ្វើស្រែជាមួយឪពុកម្តាយដល់ឆ្នាំណា បានចេញពីផ្ទះ?

ណុប មុំ:	ខ្ញុំឆ្នាំ៧៤ហើយបានចេញទៅ គេឲ្យទៅធ្វើទំនប់ប្រឡាយអីហ្នឹង ។

ឡុង ដានី:	ចឹងឆ្នាំ៧៤មីងចេញទៅណាទៅ?

ណុប មុំ:	ចេញទៅធ្វើទំនប់ប្រឡាយ ។

ឡុង ដានី:	ធ្វើនៅកន្លែងណា?

ណុប មុំ:	ធ្វើទំនប់ពកត្របែក ។

ឡុង ដានី:	នៅកន្លែងណាហ្នឹង?

ណុប មុំ:	ទៅខាងលិចក្បែរភ្នំដីវីរមៀលនោះ ។

ឡុង ដានី:	ចឹងយើងចេញធ្វើទំនប់ប្រឡាយហ្នឹងតាំងពីឆ្នាំ៧៤?

ណុប មុំ:	ចាស!កាលហ្នឹងអាយុ១៣-១៤ឆ្នាំហ្នឹង ។

ឡុង ដានី៖ ចឹងនៅស្រុកភូមិយើងកាលហ្នឹងពីណាជាអ្នកគ្រប់គ្រង?

ណុប មុំ៖ កាលហ្នឹងទៅធ្វើគ្រប់គ្នាប្រធានឃុំមិនដឹងជាឈ្មោះអីៗទេ មេឃុំមេភូមិអីគេឲ្យយើងទៅ ។

ឡុង ដានី៖ ចឹងនៅក្នុងស្រុកភូមិយើងខាងលន់ នល់គ្រប់គ្រងឬមួយខាងរំដោះគ្រប់គ្រង?

ណុប មុំ៖ កាលហ្នឹងខាងរំដោះហើយ ។

ឡុង ដានី៖ ចឹងគេរំដោះតាំងពីឆ្នាំណាភូមិហ្នឹង?

ណុប មុំ៖ កាលហ្នឹងមិនមែនរំដោះទេ នៅពេញសង្គ្រាមហើយ នៅវៃគ្នាកាលហ្នឹង៧៤មិនទាន់នេះ ណាដល់៧៥នោះបានបែក ។

ឡុង ដានី៖ ចឹងនៅឆ្នាំ៧៤មីងរស់នៅតំបន់នេះ?

ណុប មុំ៖ នៅតំបន់ហ្នឹង ។

ឡុង ដានី៖ ចឹងមានខ្មែរក្រហមនៅក្នុងហ្នឹងហើយ?

ណុប មុំ៖ មានទ័ពមានទាហាន ។

ឡុង ដានី៖ ចឹងកាលហ្នឹងស្ថានភាពស្រុកទេសយ៉ាងម៉េចទៅកាលឆ្នាំ៧៤អីហ្នឹង ខាងលន់ នល់មានចូលមកទេ?

ណុប មុំ៖ អត់ទេ តែមានការទម្លាក់គ្រាប់បែក ឡានហោះទម្លាក់ មានគ្រាប់ផ្លោងមកពីខាងអង្គតាសោមមក ។

ឡុង ដានី៖ ចឹងកាលឆ្នាំ៧៤ហ្នឹងយើងហូបបាយតាមផ្ទះឬមួយហូបរួមហើយ?

ណុប មុំ៖ កាលហ្នឹងដូចជាហូបរួមហើយ ខ្ញុំមិនសូវចាំដែរ ។

ឡុង ដានី៖ ចឹងមីងកាលបែកឆ្នាំ៧៥ទៅមីងទៅនៅណាវិញ?

ណុប មុំ៖ ខ្ញុំនៅធ្វើពេទ្យអីទៅ ។

ឡុង ដានី៖ ធ្វើពេទ្យនៅណា?

ណុប មុំ៖ ពេទ្យកាលហ្នឹងនៅអង្គជ័យ ។

ឡុង ដានី៖ ចឹងកាលហ្នឹងអាយុប៉ុន្មានហើយ?

ណុប មុំ៖ អាយុ១៩ឆ្នាំហើយ ។

ឡុង ដានី៖ ចឹងយ៉ាងម៉េចបានជាមីងធ្វើពេទ្យនៅអង្គជ័យវិញ?

ណុប មុំ៖ គេចេះតែរើសទៅ គេចាត់តាំងទៅ ។

ឡុង ដានី៖ ចឹងពីណាគេជាអ្នករើសទៅ?

ណុប មុំ៖ តាមភូមិហ្នឹងតាមឃុំហ្នឹងគេជាអ្នករើស ។

ឡុង ដានី៖ មានចាំឈ្មោះដែលជាអ្នករើសមីងទៅទេ?

ណុប មុំៈ មិនបានចាំដែរហ្នឹង ខ្ញុំភ្លេចហើយប្រធានភូមិកាលហ្នឹង ។

ឡុង ដានីៈ មីងទៅម្នាក់ឯងឬមានគេដែរ?

ណុប មុំៈ ទៅគ្នាច្រើនដែរ មានគ្នាបួនដប់នាក់ ។

ឡុង ដានីៈ កាលហ្នឹងពីណាខ្លះ?

ណុប មុំៈ ភ្លេចអស់ហើយមិនដឹងជាពីណាពីណីទេ កាលរត់ទៅស្លាប់អស់ហើយ ។

ឡុង ដានីៈ មាននៅចាំឈ្មោះខ្លះទេ?

ណុប មុំៈ អត់ទេ ។

ឡុង ដានីៈ ដូចថាបងប្អូនមីងដែលឬអ្នកស្រុកអ្នកភូមិ?

ណុប មុំៈ អ្នកស្រុកអ្នកភូមិគេរើសទៅគ្រប់គ្នា ។

ឡុង ដានីៈ ចឹងកាលហ្នឹងមីងមានបងប្អូននៅអន្តរជ័យដែលឬអត់ទេ?

ណុប មុំៈ អត់ទេ ទៅជាមួយគេឯង ។

ឡុង ដានីៈ ចឹងមីងមានស្គាល់អ្នកធ្វើការនៅអន្តរជ័យហ្នឹងទេ?

ណុប មុំៈ ភ្លេចអស់ហើយ កាលហ្នឹងយូរដែលហើយ៣០ទៅ៤០ឆ្នាំហើយ ។

ឡុង ដានីៈ ចឹងនៅខាងអន្តជ័យហ្នឹងច្រើនអ្នកពីស្រុកភូមិហ្នឹងទៅគ្រប់គ្រងឬមួយយ៉ាងម៉េច?

ណុប មុំៈ ទៅគ្រប់តែស្រុក មុំគេអន្តរជ័យក៏មាន ។

ឡុង ដានីៈ ចឹងមមីងមានចាំថា កាលគេជ្រើសរើសយើងទៅធ្វើពេទ្យហ្នឹងមុនដំបូងគេឲ្យយើងរៀនសូត្រអីទេ?

ណុប មុំៈ រៀនតិចៗហ្នឹង យើងជាពេទ្យបុគ្គលិកតូចតាចហ្នឹងមានដុកទ័រណា ។

ឡុង ដានីៈ រៀនយ៉ាងម៉េចទៅមីង?

ណុប មុំៈ រៀនអក្សរខ្មែរជំនាន់ហ្នឹង រៀនចាក់ថ្នាំអីហ្នឹង ។

ឡុង ដានីៈ ពីណាគេជាអ្នកបង្រៀនមីង មីងចាំទេ?

ណុប មុំៈ ពេទ្យគ្រប់គ្នាមិនដឹងជាអ្នកណាណី ខ្ញុំភ្លេចហើយ ។

ឡុង ដានីៈ ចឹងមីងនៅពេទ្យអន្តរជ័យហ្នឹងមីងនៅក្នុងអន្តភាពពេទ្យស្រុកឬមួយយ៉ាងម៉េច?

ណុប មុំៈ ពេទ្យស្រុក ។

ឡុង ដានីៈ ចឹងពេទ្យស្រុកហ្នឹងនៅជិតសាលាស្រុកដែរ?

ណុប មុំៈ ខ្ញុំមិនដឹងជាសាលាស្រុកនៅកន្លែងណាផង គេឲ្យទៅកន្លែងណាទៅហ្នឹងហើយ ។

ឡុង ដានីៈ ចឹងនៅក្នុងពេទ្យស្រុកហ្នឹងតែម្តង?

ណុប មុំៈ ចាស ។

ឡុង ដានីៈ ចឹងយើងទៅដំបូងយើងមិនទាន់ចេះពេទ្យអីសោះចឹង តើយើងទៅហ្នឹងគេឲ្យយើងរៀនប៉ុន្មានទៅបានគេឲ្យយើងព្យាបាលអ្នកជំងឺ?

ណុប មុំៈ ពីរបីខែហ្នឹង ។

ឡុង ដានីៈ ការងារយ៉ាងម៉េចទៅនៅក្នុងពេទ្យហ្នឹង?

ណុប មុំៈ ធ្វើគ្រប់មុខ ធ្វើពេទ្យក៏ធ្វើពលកម្មការងារស្ទូងដកក៏មានដែរ ពេទ្យធ្វើគ្រប់មុខបន្លែលើកទំនប់ក៏ទៅធ្វើ ដូចថាដាក់លវេនគ្នា ។

ឡុង ដានីៈ បាទ ។

ណុប មុំៈ មិនឲ្យតែម្នាក់ធ្វើចេះម្នាក់ៗទេ ពិបាកទាំងអស់គ្នា ។

ឡុង ដានីៈ ចឹងមានធ្វើបន្លែអីដែរ?

ណុប មុំៈ ចាស!គេចាត់តាំងយើងទៅ ទៅហើយ ។

ឡុង ដានីៈ ចឹងមានព្យាបាលអ្នកជំងឺដែរ?

ណុប មុំៈ ព្យាបាលជំងឺរបួសទូទៅហើយ គ្រប់មុខ ។

ឡុង ដានីៈ គេឲ្យមីងធ្វើអីខ្លះទៅ ដូចថាព្យាបាលយ៉ាងម៉េច?

ណុប មុំៈ ព្យាបាលរបួសជំងឺគ្រុនគ្រប់មុខ ។

ឡុង ដានីៈ ដូចថាមីងខាងចាក់ថ្នាំឬខាងបើកថ្នាំ?

ណុប មុំៈ គ្រប់មុខ ។

ឡុង ដានីៈ មានគ្នាប៉ុន្មាននាក់ទៅនៅក្នុងមន្ទីរពេទ្យអន្លុងវែងហ្នឹង?

ណុប មុំៈ មានគ្នា២០ទៅ៣០នាក់ដែរហ្នឹង តែការងារអត់មាននៅហ្នឹងដែរ គេបង្វិលរហូតហ្នឹង ។

ឡុង ដានីៈ ចឹងអ្នកទៅពីស្រុកភូមិយើងអ្នកអស់ឬមួយមានអ្នកផ្សេងដែរ?

ណុប មុំៈ មានអ្នកមកពីគ្រប់ឃុំដែលហ្នឹង គេរើសគ្រប់ឃុំមិនមែនរើសតែម្នាក់ៗឯណា ។

ឡុង ដានីៈ ចឹងប្រធានពេទ្យនៅអន្លុងវែងហ្នឹងគាត់ឈ្មោះអីទៅ?

ណុប មុំៈ មិនដឹងជាប្រធានអីៗខ្ញុំភ្លេចអស់ហើយ គាត់ស្លាប់អស់ដែរ ។

ឡុង ដានីៈ គាត់ជានារីឬមួយជាបុរស?

ណុប មុំៈ គាត់នារីដែរ ។

ឡុង ដានីៈ ចឹងគេអាយុប្រហាក់ប្រហែលមីងដែរឬមួយគេចាស់?

ណុប មុំៈ គេបង ។

ឡុង ដានីៈ គាត់អ្នកស្រុកចេញពីភូមិយើងទៅដែរ?

ណុប មុំៈ អត់ មិនដឹងជាគាត់មកពីណាពីណីយើងមិនដែលសួរឬស្គាល់គាត់ គេឲ្យធ្វើអីធ្វើហ្នឹងទៅ ។

ឡុង ដានីៈ ចឹងមីងយ៉ាងម៉េច យើងនៅទីនេះសោះយ៉ាងម៉េចគេឲ្យយើងទៅធ្វើពេទ្យនៅអន្គរជ័យ?

ណុប មុំៈ គេចាត់តាំងគេចង់ឲ្យយើងទៅណាយើងទៅហ្នឹងទៅ ជំនាន់ហ្នឹងគេឲ្យទៅណាទៅហ្នឹងហើយ ។

ឡុង ដានីៈ ចឹងមិនមែនចង់ទៅខ្លួនឯងទេ?

ណុប មុំៈ មិនចង់ទៅ គ្មានពីណាចង់ទៅបែកម៉ែឪឆ្ងាយទេ ។

ឡុង ដានីៈ ចឹងឪពុកមីងគាត់ឈ្មោះអីទៅ?

ណុប មុំៈ ប៉ាខ្ញុំស្លាប់តាំងពីយូរហើយ ។

ឡុង ដានីៈ តែគាត់ឈ្មោះអីទៅ?

ណុប មុំៈ ឈ្មោះ កែវ សាន ។

ឡុង ដានីៈ គាត់ស្លាប់តាំងពីកាល?

ណុប មុំៈ គាត់ស្លាប់តាំងពីឆ្នាំ៦៨ ។

ឡុង ដានីៈ គាត់ស្លាប់ដោយសារមូលហេតុអី?

ណុប មុំៈ ដោយសារគាត់ឈឺ ។

ឡុង ដានីៈ ចឹងម្ដាយ?

ណុប មុំៈ ម្ដាយខ្ញុំឈ្មោះ ឡេង មាយ ។

ឡុង ដានីៈ គាត់មានបងប្អូនបង្កើតប៉ុន្មាននាក់ដែរម្ដាយ?

ណុប មុំៈ មិនដឹងជាប៉ុន្មានទេ ខ្ញុំក្មេងហើយជាង១០នាក់តែមិនដឹងជាពីណាពីណីទេ តែស្លាប់អស់ហើយ ។

ឡុង ដានីៈ នៅរស់ប៉ុន្មាននាក់?

ណុប មុំៈ នៅតែអ៊ំនិងមីងពីរ ម៉ែខ្ញុំក៏ស្លាប់ ។

ឡុង ដានីៈ ចឹងម្ដាយមីងស្លាប់ពីកាល?

ណុប មុំៈ ស្លាប់ពីរឆ្នាំហើយ ។

ឡុង ដានីៈ នៅសល់អ៊ំគាត់ឈ្មោះអីដែរ?

ណុប មុំៈ នៅសល់អ៊ំ អៀកនិងមីងមុំ ឈ្មោះដូចខ្ញុំដែរ ។

ឡុង ដានីៈ ចឹងនៅសល់តែពីរហ្នឹងទេ?

ណុប មុំៈ ចាស ។

ឡុង ដានីៈ ចឹងខាងឪពុក?

ណុប មុំៈ ខាងឪពុកស្លាប់អស់យូរហើយ តាំងពីសង្គមចាស់ជំនាន់ប៉ុល ពតអីហ្នឹងមានស្លាប់ ។

ឡុង ដានីៈ ចឹងមីងមានបងប្អូនបង្កើតប៉ុន្មាននាក់?

ណុប មុំៈ ខ្ញុំមាន៧នាក់ តែស្លាប់មួយហើយកាលរត់យួន ។

ឡុង ដានីៈ មានស្រីប៉ុន្មានប្រុសប៉ុន្មាន?

ណុប មុំៈ ប្រុស៤ ស្រី៣ ។

ឡុង ដានីៈ ចឹងមីងមានបងប្អូនជីដូនមួយច្រើនទេ?

ណុប មុំៈ ច្រើនណាស់រាប់មិនអស់ទេខ្ញុំ ព្រោះយាយខ្ញុំកូនគាត់ច្រើនណាស់ ។

ឡុង ដានីៈ នៅស្រុកភូមិយើងទាំងអស់ឬក៏យ៉ាងម៉េច?

ណុប មុំៈ បែកគ្នាអស់ហើយ ខ្លះនៅអន្លង់វែង ខ្លះនៅម៉ាឡៃអីណា ។

ឡុង ដានីៈ ចឹងនៅអន្លង់វែងហ្នឹងម៉ាឡៃច្រើន?

ណុប មុំៈ ហ្នឹងសុទ្ធតែជីដូនមួយ ។

ឡុង ដានីៈ ចឹងគាត់ធ្លាប់មកលេងស្រុកទេ?

ណុប មុំៈ មកសឹកតែរាល់ឆ្នាំហ្នឹង មកធ្វើបុណ្យអីហ្នឹង ។

ឡុង ដានីៈ ចឹងគាត់មកធ្វើបុណ្យ?

ណុប មុំៈ ចាស ។

ឡុង ដានីៈ ចឹងកាលមីងនៅធ្វើពេទ្យនៅអង្គជ័យហ្នឹងមីងនៅពេលបានរយៈពេលប៉ុនានដែរ?

ណុប មុំៈ ទាល់ដល់ឆ្នាំ៧៧អីគេឲ្យមកធ្វើការនៅសាលាដើមចំបក់ហ្នឹងកាលឆ្នាំ៧៧-៧៨ហ្នឹង ។

ឡុង ដានីៈ ចឹងមីងថាធ្លាប់ទៅធ្វើការនៅកោះអណ្តែតដែរ?

ណុប មុំៈ កោះអណ្តែតហ្នឹងគេឲ្យទៅជួយព្យាបាលប្រជាជនចឹងទៅ ។

ឡុង ដានីៈ ចឹងគេឲ្យទៅជួយព្យាបាលប្រជាជនទៅកោះអណ្តែត?

ណុប មុំៈ ចាស!ជួយព្យាបាលប្រជាជនឈឺអីហ្នឹង ចុះតាមភូមិឃុំចឹងទៅ ។

ឡុង ដានីៈ ចឹងពីណាគេអ្នកដែលឲ្យទៅព្យាបាល?

ណុប មុំៈ អង្គការគេបេះតែចាត់តាំងទៅ ។

ឡុង ដានីៈ អង្គការអ្នកចាត់តាំងហ្នឹងឈ្មោះអីគេទៅ?

ណុប មុំៈ ឈ្មោះអីៗខ្ញុំភ្លេចហើយ នៅតូចៗដែរបានជាមិនសូវចាំហ្នឹង ២០ទៅ៣០ឆ្នាំហើយ ។

ឡុង ដានីៈ ចឹងចាត់តាំងឲ្យទៅព្យាបាលប្រជាជននៅកោះអណ្តែតហ្នឹងរយៈពេលប៉ុន្មានទៅ?

ណុប មុំៈ ទៅប្រហែលជាមួយខែហ្នឹង ។

ឡុង ដានីៈ ទៅមួយខែប្រហែលជាឆ្នាំណា?

ណុប មុំៈ ឆ្នាំ៧៦ ។

ឡុង ដានី: ចឹងព្យាបាលមួយខែហើយយ៉ាងម៉េចទៀត   យើងស្នាក់នៅកោះអណ្តែតហ្នឹងឬមួយយ៉ាង ម៉េចទៀត?

ណុប មុំ: អត់ផងមកនៅសាលាដើមចំបក់វិញ ។

ឡុង ដានី: កាលហ្នឹងមីងមានស្គាល់គេច្រើនទេ កាលនៅកោះអណ្តែត?

ណុប មុំ: មិនសូវស្គាល់ទេ ស្គាល់តែពេទ្យយុំតែក្មេងអស់ហើយ មិនដឹងជាឈ្មោះអីៗយូរហើយតាំង ពីនៅតូចៗម្លេះ ។

ឡុង ដានី: ចឹងកាលនៅកោះអណ្តែតហ្នឹងគណៈស្រុកគេឈ្មោះអីទៅ?

ណុប មុំ: មិនដឹងជាឈ្មោះអី មិនដែលជួបគណៈស្រុកហ្នឹងផង ខ្ញុំនៅតែកន្លែងពេទ្យ ។

ឡុង ដានី: ចឹងកាលនៅអន្គជ័យ?

ណុប មុំ: នៅអន្គរជ័យក៏មិនដឹងស្រុកគេឈ្មោះអីៗ   យើងនៅតែកន្លែងពេទ្យ   គេផ្លាស់ប្តូរមិនដឹងជា ប៉ុន្មាននាក់ ។

ឡុង ដានី: ចឹងមីងយ៉ាងម៉េចបានជាគេផ្លាស់មកនៅសាលាដើមចំបក់ហ្នឹង?

ណុប មុំ: ចុះយួនវ៉ៃចូលមកមិនរត់សើច.... យួនចូលមកមិនរត់ ។

ឡុង ដានី: ចឹងយ៉ាងម៉េចបានជាគេផ្លាស់ពីអន្គរជ័យមកសាលាដើមចំបក់?

ណុប មុំ: ចុះគេផ្លាស់មកនៅហ្នឹង ។

ឡុង ដានី: ពីណាគេជាអ្នកផ្លាស់មក?

ណុប មុំ: អន្គការគេឲ្យមកនៅហ្នឹងទាំងអស់គ្នា គេប្រាប់ឲ្យមកចេះតែមកទៅ ។

ឡុង ដានី: កាលជំនាន់ហ្នឹងគេថាអន្គការៗពីណាគេជាអន្គការហ្នឹង?

ណុប មុំ: ពួកគេថាអន្គការៗ គេចាត់តាំងមកយើងចេះតែមកទៅណាស់ ។

ឡុង ដានី: បាទ ។

ណុប មុំ: ពិបាកណាស់គ្រប់តែកន្លែងមិនដែលបាននៅមួយកន្លែងណា ។

ឡុង ដានី: ចឹងមីងមកនៅកន្លែងសាលាដើមចំបក់ហ្នឹងធ្វើអីទៅ ឬពេទ្យដដែលឬមួយយ៉ាងម៉េច?

ណុប មុំ: ធ្វើពេទ្យដដែលហ្នឹង ។

ឡុង ដានី: ធ្វើពេទ្យទៀត?

ណុប មុំ: ចាស ។

ឡុង ដានី: ចឹងធ្វើពេទ្យហ្នឹងព្យាបាលយ៉ាងម៉េចទៅនៅសាលាដើមចំបក់ហ្នឹង?

ណុប មុំ: ព្យាបាលជំងឺទូទៅ អ្នករបួសអីក៏ព្យាបាលដែលជំនាន់ហ្នឹង វ៉ៃយួនវ៉ៃអីហ្នឹង កាលយួនចូល ហ្នឹងមិនមានវ៉ៃគ្នា ។

ឡុង ដានីៈ ចឹងសាលាដើមចំបក់ហ្នឹងជាពេទ្យរបស់ស្រុកត្រាំងកក់ឬមួយយ៉ាងម៉េច?

ណុប មុំៈ មិនដឹងជាពេទ្យអីផងទេខ្ញុំមិនសូវដឹងដែរ គេឲ្យមកនៅហ្នឹងគេតែមកនៅទៅ ។

ឡុង ដានីៈ ចឹងនៅព្យាបាលហ្នឹងដូចជាប្រជាជនអីមិនព្យាបាលទេ?

ណុប មុំៈ ប្រជាជនក៏ព្យាបាលគ្រប់មុខ ។

ឡុង ដានីៈ ចឹងមីងនៅតែក្នុងពេទ្យទេ មិនបានចេញទៅព្យាបាលនៅខាងក្រៅទេ?

ណុប មុំៈ ហ្នឹងនៅតែពេទ្យ ។

ឡុង ដានីៈ គ្នាច្រើនទេ ពេទ្យហ្នឹង?

ណុប មុំៈ ច្រើនដែរ ។

ឡុង ដានីៈ ប្រហែលជាប៉ុន្មាន?

ណុប មុំៈ ប្រហែលជា២០ទៅ៣០នាក់ដែរ ។

ឡុង ដានីៈ មកពីអង្គជ័យទាំងអស់?

ណុប មុំៈ មិនដឹងជាមកពីខាងណាខ្លះទេ ពេទ្យមិនដែលនៅមួយកន្លែងផង ខ្លះផ្លាស់ទៅនោះខ្លះផ្លាស់ទៅនេះ ខ្លះគេទៅខេត្តឆ្ងាយៗដូចជាខត្តរអីណា ។

ឡុង ដានីៈ ចឹងកងទ័ពដែលត្រូវរបួសវៃជាមួយយួនហ្នឹងវៃនៅកន្លែងណាទៅ?

ណុប មុំៈ មិនដឹងជាម្តុំណាខ្លះ ដឹងតែព្រំដែនយួន ។

ឡុង ដានីៈ ព្រំដែនខាងណា?

ណុប មុំៈ មិនព្រំដែនណា ។

ឡុង ដានីៈ មានរបួសច្រើនដែលកាលហ្នឹង?

ណុប មុំៈ មានរបួសច្រើនស្លាប់ច្រើនណាស់ ខ្មែរងាប់ជិនាន់ហ្នឹងច្រើនដែរ ។

ឡុង ដានីៈ ចឹងមីងនៅហ្នឹងរហូតដល់ពេលរត់យួនតែម្តង?

ណុប មុំៈ ចាស ។

ឡុង ដានីៈ ចឹងមីងអាចរៀបរាប់នៅពេលយួនចូលមកយើងរត់អីយ៉ាងម៉េច?

ណុប មុំៈ រត់បេះតែរត់ទៅ ឡើងភ្នំអត់បាយអត់ទឹក ។

ឡុង ដានីៈ ចឹងរត់ទៅយ៉ាងម៉េចទៅ សកម្មភាពយើងរត់ទៅជាមួយពីណាខ្លះ? ម៉េចបានជាយើងរត់យ៉ាងម៉េចបានជាយើងមិននៅក្នុងភូមិ?

ណុប មុំៈ ចុះយើងនៅយ៉ាងម៉េចបានបើកគេផ្លោងគ្រាប់ដូចបាចអង្គកាម គេវៃគ្នាយើងមិនរត់នៅយ៉ាងម៉េចបាន ។

ឡុង ដានីៈ កាលរត់ទៅជាមួយពីណាខ្លះ?

ណុប មុំៈ ទៅគ្នាច្រើនគ្រប់តែគ្នា ភូមិហ្នឹងមានពីណានៅមួយ ។

ឡុង ដានីៈ កាលហ្នឹងរត់ទៅដល់ណាទៅ?

ណុប មុំៈ ឡើងភ្នំច្រើនខ្ញុំមិនដឹងថាជាភ្នំអីៗទេ ភ្នំរាប់រយរាប់ពាន់ ។

ឡុង ដានីៈ ដល់កន្លែងណាទៅបានមីងចុះមកវិញ?

ណុប មុំៈ មិនដឹងជាភ្នំអីៗដល់ហើយចុះមកវិញទៅ ។

ឡុង ដានីៈ មកដល់វិញឆ្នាំណាខែណា?

ណុប មុំៈ កាលហ្នឹងខែ៥ឆ្នាំ៧៩ ។

ឡុង ដានីៈ មកជាមួយពីណាខ្លះទៅ?

ណុប មុំៈ មកគ្នាច្រើនដែលហ្នឹង តែរត់ទៅវាស្លាប់អស់ហើយនៅសល់តែបួនប្រាំនាក់ កាលមកយប់ត្រង់ណាដេកត្រង់ហ្នឹងទៅ ។

ឡុង ដានីៈ បួនប្រាំនាក់ហ្នឹងពីណាខ្លះទៅ?

ណុប មុំៈ គេនៅឆ្ងាយៗ មិនដឹងជាពីណាពីណី ។

ឡុង ដានីៈ ចឹងមីងរៀបការឆ្នាំណា?

ណុប មុំៈ ខ្ញុំឆ្នាំ៨០ ។

ឡុង ដានីៈ ឆ្នាំ៨០ពេលមកដល់ស្រុកភូមិវិញហើយ?

ណុប មុំៈ ចាស ។

ឡុង ដានីៈ ចឹងគាត់ធ្វើអីដែរ?

ណុប មុំៈ ធ្វើស្រែដែរ ។

ឡុង ដានីៈ អត់ទេ កាលពីសម័យបីឆ្នាំ?

ណុប មុំៈ ធ្វើកងចល័តកងអីហ្នឹង ។

ឡុង ដានីៈ គាត់អាយុប៉ុន្មានដែរ? គាត់អាយុស្រករមីងឬច្រើនជាង?

ណុប មុំៈ ស្រករគ្នាដំណាលគ្នាហ្នឹង ។

ឡុង ដានីៈ ចឹងមីងមានបងប្អូននៅខាងប៉ៃលិនអន្លង់វែងអីមីងមានដែលទៅលេងពួកគាត់ដែរ?

ណុប មុំៈ ទៅ ។

ឡុង ដានីៈ ចឹងខស្ប្រាហ៍ទៅលេងដែរ?

ណុប មុំៈ ចាស ។

ឡុង ដានីៈ គាត់នៅប៉ៃលិនម្តុំណាកាលមុនខ្ញុំធ្លាប់ទៅលេងដែរ?

ណុប មុំៈ ប៉ៃលិនខ្ញុំមិនដែលទៅទេ ខ្ញុំធ្លាប់ទៅតែអន្លង់វែងទេ ម៉ាឡៃហ្នឹង ។

ឡុង ដានីៈ អូ!ម៉ាឡៃ ខ្ញុំកាលមុនទៅម៉ាឡៃនិងអន្លង់វែងដែរ ទៅម្តុំផ្សារអីដែរ ចឹងបងប្អូនមីងនៅម្តុំណាទៅ?

ណុប មុំៈ នៅខាងលិចផ្សារអន្លង់វែង ។

ឡុង ដានីៈ ទៅលេងយូរៗទេ ខាងអន្លង់វែង?

ណុប មុំៈ ខ្ញុំទៅបានមួយឆ្នាំដែរ ទៅចាំដី ។

ឡុង ដានីៈ ទៅចាប់ដី?

ណុប មុំៈ បានដីមួយក្បាល ។

ឡុង ដានីៈ នៅម្តុំណា?

ណុប មុំៈ នៅអន្លង់វែងហ្នឹង គេហៅទួលស្វាយ ផ្សារទើបធ្វើថ្មី ។

ឡុង ដានីៈ នៅទួលស្វាយ ខាងត្រពាំងតាវអីហ្នឹង?

ណុប មុំៈ ចាស ។

ឡុង ដានីៈ ចឹងយ៉ាងម៉េចបានជាមីងទៅចាប់ដីនៅហ្នឹងបាន?

ណុប មុំៈ បងប្អូននៅហ្នឹងគាត់ហៅទៅ ។

ឡុង ដានីៈ ចឹងបងប្អូននៅហ្នឹងធ្វើការដែរ បានទៅចាប់ដីបាន?

ណុប មុំៈ គាត់មានធ្វើអីផងប្រជាជនផងហ្នឹង គាត់ធ្វើមេឃុំអីដែរ ។

ឡុង ដានីៈ ធ្វើមេឃុំត្រពាំងតាវហ្នឹង?

ណុប មុំៈ ចាស ។

ឡុង ដានីៈ ពីណាគេឈ្មោះអី ខ្ញុំធ្លាប់ទៅធ្វើការនៅហ្នឹងដែរ?

ណុប មុំៈ ឈ្មោះយាយ ថែម ស្គាល់ដែរ ។

ឡុង ដានីៈ ខ្ញុំស្គាល់គាត់តើ ខ្ញុំធ្លាប់ជួបគាត់ដែរ ។

ណុប មុំៈ ចឹង ។

ឡុង ដានីៈ គាត់ត្រូវជាយ៉ាងម៉េចជាមួយមីង?

ណុប មុំៈ ត្រូវជាអីឆ្ងាយដែលហ្នឹង តែគាត់ឃើញខ្ញុំកូនច្រើនចេះតែជួយទៅ អ្នកក្រៅក៏ជួយដែរ គាត់ចិត្តល្អ ។

ឡុង ដានីៈ យាយ គាត់ត្រូវជាបងប្អូនយ៉ាងម៉េចជាជីដូនមួយឬជីទួតមួយ?

ណុប មុំៈ ជីទួត ។

ឡុង ដានីៈ គាត់មានធ្លាប់មកស្រុកយើងដែលអត់?

ណុប មុំៈ គាត់មកធ្វើបុណ្យ មកឆ្នាំទៅមិញ ។

ឡុង ដានី:	ចឹងគាត់មកកាលឆ្នាំទៅដែរ?

ណុប មុំ:	ចាស!គាត់មកធ្វើបុណ្យ «កូនមីងមុំនិយាយថា យាយទៅណាក៏គាត់មិនខ្លាចដែលព្រោះគាត់មិនដែលបានធ្វើអាក្រក់ផង អត់មានបេះខ្លាចពីណារលីង» ។

ឡុង ដានី:	ចឹង?

ណុប មុំ:	គាត់ថាជំនាន់ណាក៏មិនបានធ្វើអាក្រក់ដែរ ។

ឡុង ដានី:	គាត់មកធ្វើបុណ្យគ្រួសារគាត់នៅហ្នឹង?

ណុប មុំ:	គ្រួសារគាត់នៅជាមួយគ្នាដែលហ្នឹង នៅអន្លង់វែង តែនៅនេះម៉ែឪជីដូនជីតាគាត់នៅទីនេះ ។

ឡុង ដានី:	ចឹងមីងជីដូនជីតាគាត់នៅហ្នឹង?

ណុប មុំ:	ចាស! តែម៉ែឪគាត់ស្លាប់អស់ហើយ ធ្វើបុណ្យឲ្យតាគាត់ ។

ឡុង ដានី:	ធ្វើបុណ្យឲ្យឈ្មោះអីខ្លះ?

ណុប មុំ:	មិនដឹងជាឈ្មោះអីៗឈ្មោះអីទេ តាពីដើមមកគាត់ស្លាប់អស់ហើយ ។

ឡុង ដានី:	បាទ ។

ណុប មុំ:	ស្លាប់យូរហើយតាំងពីសង្គមចាស់ ពីរបីជំនាន់មកហើយ ។

ឡុង ដានី:	ចឹងផ្ទះគាត់កាលមុនជំនាន់បីឆ្នាំគាត់នៅណាទៅ?

ណុប មុំ:	នៅភូមិនេះ ។

ឡុង ដានី:	ភូមិណាទៅ?

ណុប មុំ:	ភូមិជាមួយគ្នាហ្នឹង ។

ឡុង ដានី:	ដីគាត់នៅហ្នឹង ឥឡូវនៅជាដីគាត់ឬមួយយ៉ាងម៉េច?

ណុប មុំ:	ឥឡូវដីរដ្ឋគេចែកគ្នាអស់ហើយ ។

ឡុង ដានី:	ចឹងផ្ទះហ្នឹងមិនមែនផ្ទះគាត់ទៀតទេ?

ណុប មុំ:	អត់ទេ មានផ្ទះណាជំនាន់ហ្នឹងគេរុះអស់រលីងហើយ ជំនាន់ប៉ុល ពតគេរុះអស់រលីង ។

ឡុង ដានី:	ចឹងគាត់មកធ្វើបុណ្យធ្វើយ៉ាងម៉េចទៅបើគាត់មិនមានផ្ទះអីផងហ្នឹង?

ណុប មុំ:	គាត់មកផ្ទះបងប្អូននៅទីនេះ គាត់ស្នាក់នៅទៅ ។

ឡុង ដានី:	ចឹងគាត់ស្នាក់នៅផ្ទះមីងដែរ?

ណុប មុំ:	ចាស ។

ឡុង ដានី:	ចឹងភាគច្រើនគាត់មកធ្វើបុណ្យគាត់ដេកនៅផ្ទះមីង?

ណុប មុំ:	មិនទេ ជួនកាលគាត់ទៅដេកផ្ទះបងប្អូនគាត់នៅត្បូងទៅ គាត់មានបងប្អូននៅផ្សេងទៀត ។

ឡុង ដានី៖ នៅភូមិណា?

ណុប មុំ៖ នៅភូមិនមោអីហ្នឹង ។

ឡុង ដានី៖ ចឹងដូដីដូនដីតាគាត់នៅណាទៅ?

ណុប មុំ៖ ដូខ្ទិចខ្ទីរអស់ហើយហ្នឹង ធ្វើចេតីយ៍ធ្វើគ្រប់តែគ្នាមិនមែនធ្វើតែគាត់ណា ធ្វើមួយភូមិទទឹង ថ្ងៃហ្នឹងធ្វើទាំងអស់គ្នា ។

ឡុង ដានី៖ ចឹងធ្វើចូលគ្នា?

ណុប មុំ៖ តាំងពីដើមមកធ្វើចូលគ្នាចឹងចាស់ៗពីដើមមក ។

ឡុង ដានី៖ ចឹង?

ណុប មុំ៖ មានអ្នកខ្លះនៅភូមិនោះទៅអ្នកនេះទៅមកគ្រប់តែភូមិហ្នឹង ដល់ខែគេធ្វើចឹងមកជុំគ្នាតែមួយថ្ងៃចឹងតែម្តង ។

ឡុង ដានី៖ ចឹងចេតីយ៍មួយហ្នឹងមិនមែនតែក្រុមគ្រួសារគាត់ទេ?

ណុប មុំ៖ មិនមែនទេ ពីដើមដាក់រួមគ្នា ឥឡូវហ្នឹងក៏ចឹងដែរ រាប់រយរាប់ពាន់នាក់ ជុំគ្នានៅហ្នឹងអាស្លាប់ជំនាន់ក្រោយក៏នៅហ្នឹងអាស្លាប់ជំនាន់មុនក៏នៅហ្នឹង ធ្វើទំនើរជាន់លើគ្នាចឹងទៀតទៅមិនដឹងជាប៉ុន្មានតមកហើយ ។

ឡុង ដានី៖ ចឹងគាត់មករាល់តែឆ្នាំដែរ?

ណុប មុំ៖ ដូនកាលគាត់មក ដូនកាលគាត់មិនបានមក គាត់ធ្វើមេឃុំតែគាត់មិនមានលុយ ។

ឡុង ដានី៖ ចឹងគាត់ធ្វើមេឃុំតែគាត់មិនមានលុយ?

ណុប មុំ៖ អត់មានលុយ ។

ឡុង ដានី៖ ចឹងពេលមឹងនៅអន្លង់វែងមឹងនៅស្នាក់នៅផ្ទះគាត់?

ណុប មុំ៖ អត់ទេ ខ្ញុំទៅនៅកន្លែងដីខ្ញុំ ។

ឡុង ដានី៖ អត់ទៅនៅផ្ទះគាត់ទេ?

ណុប មុំ៖ អត់ទេ ។

ឡុង ដានី៖ ចឹងកាលនៅចាប់ដីហ្នឹង គាត់មឹងហៅមឹងទៅ?

ណុប មុំ៖ គាត់ហៅតែគ្រប់គ្នាហ្នឹងពីណាអត់មានដី អ្នកអត់មានដីទីលំនៅអីហ្នឹង គាត់ចេះតែហៅទៅទោះមិនមែនបងប្អូនក៏ដោយ ទៅច្រើនតែហ្នឹង ដល់ចឹងស្គាល់គ្នាចេះតែហៅចឹងទៅ ចាប់ដីនៅហ្នឹងធ្វើស្រែទៅ នៅនេះដី១០អា២០អាកូន៧-៨នាក់ហូបអីគ្រាន់ លក់ដីនេះទៅនៅនោះតែម្តងទៅ កាលហ្នឹងគេនៅធូរវាចឹងទេ“កូនប្រសាប្រុសមឹងមុំនិយាយ” ចប់ត្រឹមអត់គេរត់តែម្តងបើគេមានគេមិនទៅទេ ។

ឡុង ដានី៖ ចឹងគាត់អត់មានបងប្អូនទេនៅនេះ បងប្អូនបង្កើតគាត់?

ណុប មុំ៖ ដីដូនមួយក៏គ្មានដែរ គាត់ចាស់ជិនាន់មុន។

ឡុង ដានី៖ បងប្អូនគាត់ទៅនៅអន្លង់វែងម៉ាខ្សែអស់ឬមួយយ៉ាងម៉េច?

ណុប មុំ៖ គាត់មានបងប្អូនតែពីរនាក់នៅផ្ទះក្បែរគ្នាហ្នឹងឈ្មោះជី។

ឡុង ដានី៖ ឈ្មោះស៊ី?

ណុប មុំ៖ ឈ្មោះជី។

ឡុង ដានី៖ យាយ ជី។

ណុប មុំ៖ នៅផ្ទះក្បែរគ្នាហ្នឹង។

ឡុង ដានី៖ គាត់ឈ្មោះអីចែម?

ណុប មុំ៖ អ៊ឹម ចែម។

ឡុង ដានី៖ ឪពុកគាត់ឈ្មោះអ៊ឹមឬយ៉ាងម៉េច?

ណុប មុំ៖ ជីតាគាត់។

ឡុង ដានី៖ ចឹងឪពុកគាត់ឈ្មោះអី?

ណុប មុំ៖ មិនដឹងជាឈ្មោះអី ខ្ញុំមិនសូវស្គាល់ដែលហ្នឹង បងប្អូនសាច់ឆ្ងាយហើយ។

ឡុង ដានី៖ ចឹងប្ដីគាត់អ្នកស្រុកភូមិយើងដែរ?

ណុប មុំ៖ នៅភូមិហ្នឹង ប្ដីគាត់ឆ្គួតទៀត។

ឡុង ដានី៖ តែពេលមកបុណ្យអីប្ដីគាត់មកដែរ?

ណុប មុំ៖ មកដែរ។

ឡុង ដានី៖ កូនគាត់មកដែរ?

ណុប មុំ៖ មក។

ឡុង ដានី៖ ឆ្នាំហ្នឹងគាត់ទើបមកដែរ?

ណុប មុំ៖ មកកាលឆ្នាំទៅមិញនោះ ឆ្នាំហ្នឹងមិនដឹងជាបានមកអត់។

ឡុង ដានី៖ ធ្វើបុណ្យភាគច្រើនគេធ្វើខែណា?

ណុប មុំ៖ ខែចែត ខែ៣។

ឡុង ដានី៖ ចឹងរាល់ឆ្នាំគេច្រើនធ្វើខែ៣?

ណុប មុំ៖ ខែ៣។

ឡុង ដានី៖ ចឹងមួយឆ្នាំគេធ្វើតែម្ដងឬយ៉ាងម៉េច?

ណុប មុំៈ យើងធ្វើម្តងតាមរដូវចូលឆ្នាំចិនទៅ បើអ្នកឆ្ងាយពីរឆ្នាំគេមកម្តងចឹងទៅ ចុះពិបាកដែល សាហ៊ុយទៅមកអស់ច្រើន មកម្នាក់អស់១០ម៉ឺនបើមកបីបួននាក់ឃើញហើយ ។ “កូនប្រុសារមីងមុំនិយាយ” ។

ឡុង ដានីៈ ចឹងគ្រប់គ្នាឲ្យតែអ្នកមានសាច់ញាតិមកចំថ្ងៃហ្នឹងតែម្តង?

ណុប មុំៈ ហ្នឹងហើយ ។

ឡុង ដានីៈ យើងណាត់ថ្ងៃ?

ណុប មុំៈ យើងដឹងថ្ងៃដឹងខែតែម្តង ប្រចាំឆ្នាំដល់ថ្ងៃហ្នឹងខែហ្នឹងត្រូវតែធ្វើ ។

ឡុង ដានីៈ ចឹងមីងធ្វើបុណ្យជាមួយគ្នាដែរ?

ណុប មុំៈ ខ្ញុំអត់ផង ដូនតាខ្ញុំនៅលិចនោះ ។

ឡុង ដានីៈ ចឹងនៅលិច?

ណុប មុំៈ ចាស ។

ឡុង ដានីៈ ចឹងគាត់មកធ្វើបុណ្យខែ៣ដឹងថ្ងៃណាទេ?

ណុប មុំៈ ខ្ញុំមិនដឹងថាថ្ងៃណាៗទេ ។

ឡុង ដានីៈ បើយើងធ្វើបុណ្យជាមួយគាត់បានដឹង?

ណុប មុំៈ ចាស ។

ឡុង ដានីៈ មីងមានត្រូវទៅលេងអន្លង់វែងទៀតទេ?

ណុប មុំៈ ខ្ញុំមិនដឹងជាកាលបានទៅទេ ។

ឡុង ដានីៈ ដីពីណាមើលទៅពេលមីងមកចឹង?

ណុប មុំៈ ប្អូនខ្ញុំនៅហ្នឹង ។

ឡុង ដានីៈ ចឹងប្អូននៅហ្នឹងដែរ?

ណុប មុំៈ ចាស ។

ឡុង ដានីៈ ខ្ញុំដូចជាអស់អីចង់សួរមីងទៀតហើយ តើមីងមានអីចង់សួរពួកខ្ញុំទៀតទេ?

ណុប មុំៈ អត់ទេ ។

ឡុង ដានីៈ ចឹងខ្ញុំអរគុណមីងច្រើន ។

ណុប មុំៈ ចាស ។

**ចប់**